Khmer Story Lovers

ប្រកាសជូនដំណឹង

— ចំណាត់ការនៃក្រុមអ្នកនិពន្ធកាសែតរួមមិត្តលេខ ២៥ ផ្លូវលេខ ២៧៩ ជីក្បត់លេខ ២៥៩ ប៊ីងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

ប្រុងបារម្ភសោកសង្រេងផ្សាយរៀងរាល់ថ្ងៃ

ឬតម្រៀបដោយ: អ.គីមសាន

តម្លៃ: 25 ₹

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
« មាតុភូមិ »
ភ្នំពេញ
លេខ ៣៥

ស៊ីផាននិងកញ្ញា :

–មែនហើយ ! ពួកភ្នំទឹកកកដែលតាមចាប់ខ្ញុំប្រើនលើកប្រើនគ្រា, ប្លាស់ជាមានរឿងសំខាន់ណាស់ ! ប៉ុន្តែតើគ្រូនឹងពួកគាត់យោគយល់ដល់ម្ចាស់ភូមិមាន សាន្តស្ងប់ផែវឬ ? តើមគ្រាន់តែហៅទៅស្តីបន្ទោស ប្រដៅប្រដោសបន្តិច រេរៀងមកវិញទេដឹង ?

ទិដ្ឋភូតសង្ឃឹតញញែ :

– ហ៊ុំ ! បងនិយាយដូចជាងាយពេក, បងឯងលួងដឹណាស់ ! បើចង់ស្តីបន្ទោសម៉ែបមិន "ល្អយ" ក្នុងនេះចែកអ្នកឯទៀតស្តាប់ទៅ, ចាំបាច់ខ្លាំងបញ្ជូនទៅដល់ទីតាំងភ្នំទឹកកកវិញឬយ ? ម្យ៉ាងទៀតក្នុងការបើកចាប់ម្តងនេះ, ក្រុមភ្នំទឹកកកត្រូវបានបង់ជីវិតមនុស្សច្រើនណាស់, បងមិនដឹងទេហេ ?

ស៊ីផានព្រឺក្បាលខ្លាចរំលែកសើចសង្ស័យទឹកមើញឮភ្លាមថា ក្នុងរយៈពេលមួយកន្លះខែនេះ ស្លាប់ពេកមែនណាន ស្លាប់ពេកស៊ីផុងយីនេះ, សិស្សភ្នំទឹកកកពិតជាស្លាប់ច្បាស់បង់ជីវិតច្រើនមែន ។ គ្រាន់តែជីវិតមនុស្សដូចគ្នាផុងយីគ្មានអ្វីសងគ្រប់ទៅហើយ ចំពោះអំពើឧក្រិដ្ឋដែលប្រព្រឹត្តទៅលើភ្នំទៀត, តើឲ្យដោះស្តីបន្ទោសតែមាត់បានដែរឬ ?

ទិដ្ឋភូតពោលតឆ :

- បងឆ្ងាយពិតជាមានកំហុសក្លួនមែន, ដើរតាត់ត្រូវរៀនសូត្រជាការសមរម្យណាស់, តែគួរស្តាយត្រង់លោកម្ចាស់ភូមិត្រូវស៊ីទាំងពីរនាក់ប្តីប្រពន្ធដែលជាអ្នកឲ្យហានយ៉ាងក្លាហានពុតមនុស្ស... ហ៊ឹ! មិនគួរទៅស្លាប់ជាមួយកូនកំហូចសោះ! ហ៊ឹ!...

ស៊ីផានស្តុះភ្លែតបញ្ចេញសម្លេងក្អែ:

នាង ... ចង់ថាម៉េច? លោកម្ចាស់ភូមិស៊ីទិងតវិយាត្រូវស្លាប់ជាមួយអ្នកណា?

តាំងពីដួបប្តីប្រពន្ធស៊ីលីងមក, ស៊ីផានស្រឡាញ់គោរពតាត់ណាស់ ព្រោះអ្នកស្រីពុនយូរាប់ថ្ងៃក៏ថ្មមានាយដួចកូនបង្កើត។ ទោះបីពេលនេះនាយជំងឺថាតាត់ច្រឡំ ហើយតាត់រកកូនមិនឃើញហើយ ក៏នាយនៅមានអារម្មណ៍ជឹកនាំក្តៅថា ពីរនាក់ប្តីប្រពន្ធនេះស្ថិតស្ថាលជាមួយនាយលើសអ្នកផងទាំងពួង។ ឥឡូវឮទីឆ្ងល់ថា តាត់មានគ្រោះថ្នាក់ដល់ជីវិត, នាយក៏ថ្មើមក្តុកភិតភ័យក្រៃលែង។ ទីឆ្ងល់ពោលតៈ

- លោកនាយម្ចាស់ភូមិស៊ីទិងតវិយា ត្រូវជាឪពុកម្តាយបងមានឯ, តាត់ទៅភ្ជុំទឹកកកជាមួយកូនពិតជាទៅរកក្តីស្លាប់មែន, ព្រោះកាលណាតាត់បង្ខំលន់ឈ្មោះលោកត្រូវតំណែងប៉ាយជានាយក្រុម, លោកតានោះមិនព្រមទេតាត់ថាសម្លាប់បងមានជាដាច់ខាត! ពេលនោះបងគិតមើលតង់យល់ហើយ, ឪពុកម្តាយដើរស្វែងរកកូនឃើញសេចក្តីថាស្រឡាញ់កូនប៉ុណ្ណា, ដល់ឃើញកូនមានគ្រោះថ្នាក់គាត់ត្រូវការពារកូនជាធម្មតា។ ភ្ជុំទឹកកកមានសិស្សតណាមួយ? ដួចស្រមោចហើយជាទឹកន្ទែងរបស់តែស្រាប់, បងគិតមើលគាត់ប្រយុទ្ធឈ្នះគេទេ? គាត់តំកូនវត់រួចទេ? ហ៊ឹ! ខ្ញុំសង្កេតឃើញលោកស្រីស៊ីស្រឡាញ់បងណាស់, សូម្បីម្តាយបងបង្កើតក៏ស្រឡាញ់បងមិនដល់គាត់ដែរ ពេលនេះគាត់... គាត់ត្រូវស្លាប់ចោលឆ្អឹងលើភ្ជុំទឹកកក, គួរអាសូរណាស់!

ពោលចប់នាងលើកដៃខ្ទប់មុខយំរណ្តើតរណ្តក់ទៀត។

ស៊ីផានទ្រាំសម្រាលពេញឧកពោលថា:

- បើលោកម្ចាស់ភូមិមានគ្រោះថ្នាក់ហើយ, ទោះភ្ជុំទឹកកកមានឧបសគ្គយ៉ាងណាក៏ខ្ញុំទៅជួយគាត់ដែរ។ ប៉ើជួយមិនបានខ្ញុំសុខចិត្តស្លាប់ជាមួយ គាត់មិនព្រមទៅសម្លាប់ឯងទេ។ ទីឆ្ងល់តុងៗខ្ញុំទៅហើយ!

ទីឆ្ងល់ប្រញាប់ដាញដៃមាណពវាប់:

Khmer Story Lovers

– បងគិតទៅណាហ្នឹង ?

– ខ្ញុំត្រូវទៅទាំងយប់ស្រួតឲ្យទាន់លោកម្ចាស់ភូមិដើម្បីទៅភ្ជុំទឹកកកជាមួយគាត់ដែរណា ! ។

– ហ៊ឺ ! ខ្ញុំឮគេថាលោកត្រូវតំរូវឲ្យចាំយនោះ មានឃុន្ធសិល្ប:ទាំងពូកែណាស់, មានទាំងតន្ត្រីដ៏ហូរវាន់លីអីណាទៀត, ទោះបងទាំងពូកែប៉ុណ្ណឹងក៏គ្មានសង្ឃឹម ព្រោះលើភ្នំមានអ្នកខ្លាំងគ្រឿងយន្តគ្រប់តំហានឲ្យតែបងប្រហែសខ្លួនបន្តិចបន្តួចស្លាប់ជាធ្លាក់អណ្តូងហើយ ។ ខ្ញុំហ៊ានពាយថាទោះបងមានស្លាបក៏គេចមិនផុតពីកណ្តាប់ដៃគេដែរ ។

– ប៉ុន្តែពេលនេះខ្ញុំមិនត្រូវបង្អែបង្អង់ទេម៉ែងតុង ។

– បងនៅក្មេងណាមកវាហានភ្លាន់ស្គាល់ស្លាប់ទេ ។ បើបងស្លាប់លើភ្នំទឹកកកមែន, តើលោកម្ចាស់ភូមិទាំងប្តីប្រពន្ធរស់រានមានជីវិតដែរ ? ម៉្យាងទៀត...បងស្លាប់ទៅ, ខ្ញុំមិនដឹងពិបាកយ៉ាងណាទេ ! ហ៊ឺ ! ខ្ញុំមិនអាចទ្រាំរស់តែម្នាក់ឯងបានឡើយ ។

មាណពស្តាប់ទីងតុងយំយែករៀបរាប់សព្វគ្រប់ដូចជាជំពាក់ចិត្តលើខ្លួនណាស់, ហេរវូងនាយលោតញាប់ខុសធម្មតា, នាយគោលទាំងញ័រមាត់ :

– ទីងតុង, ម៉េច...ម៉េចនាងល្អនឹងខ្ញុំម្ល៉េះ ? ខ្ញុំមិនមែនបងធានានាងឯណា ?

ទីងតុងផកដៃម្ជើមធំ :

– បងមានមុខមាត់និងរូបរាងដូចតេបេះបិទអ៊ីចឹង ខ្ញុំបែកចិត្តមិនកើតទេ, ម៉្យាងទៀតខ្ញុំរស់នៅជាមួយបងច្រើនថ្ងៃដែរ, បងស្រឡាញ់ថ្នាក់ថ្នមខ្ញុំគួរឲ្យខ្ញុំជាប់ជំពាក់ចិត្តលើបងណាស់ណា ! ។

នាងក្រមុំចាប់ដៃមាណពទាំងពីរជាប់ , គោលបន្ត :

– បងធាន, សូមសន្យានឹងខ្ញុំមក ! ទោះបីយ៉ាងណាក៏បងមិនត្រូវទៅស្លាប់ចោលខ្ញុំដែរណា ។

– តែខ្ញុំត្រូវទៅជួយលោកម្ចាស់ស៊ីជាងាប់ខាត ។

– ពេលនេះខ្ញុំនឹកឃើញគ្រោងការមួយតែខ្ញុំខ្លាចបងសង្ស័យថាខ្ញុំចិត្តអាក្រក់ទើបខ្ញុំមិនហ៊ានឱ្យ ។

ស៊ីផងានស្តីយ៉ាងប្រញាប់:

– គិតឃើញយ៉ាងម៉េចប្រាប់ខ្ញុំឆាប់មក ! ខ្ញុំយល់ចិត្តនាងបង្ហាស់លាស់ហើយ ។

ទីងតុងសញ្ជប់សញ្ជឹងរួចគោលទាំងបន្ទំ:

– បងធាន , រឿងនេះដូចជាធ្វើបាបបងពេកហើយឲ្យគេស្រណុកជ្រុល , បើអ្នកស្រីដឹងរឿងនេះ !

ប្អាស់ជាគេចោទខ្ញុំថា ជាក់អន្លាក់យើហើយ ។ ហ៊ឹ ! មិនកើតទេ , ការនេះមិនគប
សម្រេចបានឡើយ , ទោះខ្ញុំមានសង្ឃឹមយ៉ាងម៉ាក៏មិនយុត្តិធម៌ដែរ ។

ស៊ីផានអង្វរ :

សូមអាណិតគ្រាប់ខ្ញុំមក ! មធ្យោបាយយ៉ាងម៉េច ? ឲ្យតែអាចជួយលោកម្ចាស់ស៊ីនិង
លោកស្រីផុតពីក្តីស្លាប់ , ខ្ញុំសុខចិត្តរងគ្រោះខ្លះហើយ , ខ្ញុំមិនខ្លាចទេ ។

ទីឆតុងជាកដើម្បីធំមួយប្រឈមក់ទើបឆ្លើយ :

បងធាន, បើបងពិតជាចង់ឲ្យខ្ញុំនិយាយ, ខ្ញុំធ្វើតាមបងម្តងចុះ, ប៉ុន្តែចិត្តខ្ញុំមិនចង់
ឲ្យបងប្រព្រឹត្តអំពើអយុត្តិធម៌ដូចខ្ញុំនឹកឃើញទោះទេ ។ ឥឡូវខ្ញុំសុំសួរបងសិនថាហេតុអីបានជា
ក្រុមភ្នំទឹកកកស្អប់ខ្ពើមស៊ីផុនយ៉ាខ្លាំងដែម្ល៉ះ ? ហេតុអីបានជាគេកេចាប់យកទៅសម្លាប់ចោល ?

ស៊ីផានតបយ៉ាងរួសរាន់ :

-បើតាមខ្ញុំដឹង គឺស៊ីផុនយើបានទៅរៀនទៅភ្នំទឹកកក ហើយមានប្រព្រឹត្តអំពើអីមួយខុសនឹងច្បាប់
ទម្លាប់ខុសន៍ធ្ងន់ធ្ងរក្រមបក្ស ទាល់តែកូនស្រីលោកគ្រូប៉ាយស្លាប់បាត់បង់ជីវិត, នាគភ្លើងហូនរង់ចាំ
ជាប់ដៃម្នាងនិងការអ្វីៗដែលយើងមិនដឹងទៀត !

ទីឆតុងដាក់ក្បាលរួចសួរទៀត:

-ពិតណាស់, ស៊ីផុនយើសម្លាប់គេដូច្នេះបានជាគេតាមចាប់យកទៅសម្លាប់វិញ ។ បងធាន
បងមានដៃលទៅសម្លាប់កូនស្រីលោកគ្រូប៉ាយទេ

ស៊ីផានមិនដឹងមាំ :

- ខ្ញុំ . . . ឥតដៃលទេ ! មិនចាំស្គាល់មុខកូនស្រីគាត់ផង ។

- ត្រូវហើយ ! មធ្យោបាយខ្ញុំវាយលើគោក គឺខ្ញុំចង់ឲ្យបងក្លែងខ្លួនជាស៊ីផុនយើទៅគាន់ភ្នំទឹកកក
ជាមួយលោកម្ចាស់ស៊ីនិងលោកស្រី ។ ដល់ពេលគេរកសម្លាប់បង, បងបើកការពិតគ្រាប់គេថា
បងមិនមែនស៊ីផុនយើទេ, បងឈ្មោះឆ្កែឥតលួច ! ពេលនោះពួកភ្នំទឹកកកមិនសម្លាប់បងជាដាច់ខាត
ឯលោកម្ចាស់ភូមិស៊ីចាំងពីរនាក់ប្តីប្រពន្ធឥតបានទាស់ទែងឬប្រយុទ្ធជាមួយគេដែរ ។ ធ្វើយ៉ាងនេះមិន
ផុតគ្រោះថ្នាក់ចាំងអស់គ្នាឬ ?

ស៊ីផានសញ្ជឹងគិតរួចតប:

Khmer Story Lovers

- មង្សាចាយនេះប្រសើរមែន, តែពីនេះទៅក្នុងទំកកកផ្លូវឆ្ងាយណាស់មិនដឹងប៉ុន្មានគាន់តីឡូខេ, បើខ្ញុំរួមដំណើរជាមួយលោកគ្រូប៉ាយឯស្រាប់ជាបែកគាកីកីណាលផ្លូវហើយ ។ ទីនេះ តុនេះ, នាងជំនួសប្រាប់ថា ខ្ញុំមិនចេះនិយាយស្តី មិនធ្លាតវងវៃដូច . . . ដូចស៊ីជុងយីខេ ។

ទីនតុនសើចហើយតន្ទ្យល់ទៀត:

-រឿងនេះខ្ញុំគិតរួចហើយ ។ ខ្ញុំមានមេម៉ាត់សម្រាប់លាបបំពង់កឲ្យហើមធំដូចកែតបូសឬដុំចៅអីមួយរកហាមាត់និយាយមិនកើតខេ ដល់ស្រុកហើយក៏នៅពិបាកហាមាត់ដែរ ។ បងមិនត្រូវនិយាយរកអ្នកណាខេ, ធ្វើដូចមនុស្សគ្រប់ចំណែ គេវាសសរីឲ្យឡើយ ។

នាងដកដង្ហើមធំអង្គុយក្បែរគ្រែគោលទាំងស្រងូត:

-បងធាន, មង្សាចាយនេះល្អប្រសើរមែនតែមិនសូវថ្លៃថ្នូរបំពោះបងសោះ ។ ខ្ញុំពិបាកចិត្តណាស់ ។

ស៊ីជុងធានស្តាប់សំដីនេះហាក់ដូចទីនតុនស្រឡាញ់រាប់អាននាយដោយស្មោះ មិនចង់ឲ្យនាយប្រព្រឹត្តអំពើមិនគប្បីណាមួយឡើយ ។ នាយប្តេជ្ញាចិត្តថាកុំសូម្បីឲ្យធ្វើគាំងឲ្យទៅស្លាប់ដោយសារនាងក៏នាយមិនប្រកែកដែរ, . ហេតុនេះហើយបានជានាយស្រែកខ្លាំង ។:

- មង្សាចាយនាងប្រសើរណាស់ ! តែធ្វើម្តេចឲ្យខ្ញុំទៅប្តូរកន្ទែងស៊ីជុងយីបាន ?

- អូរឿងនេះបងកុំព្រួយ, ពួកគេស្នាក់នៅសណ្ឋាគារមួយឯភូមិខាងលិច, យើងទៅឥឡូវជួបគេហើយ ។ ខ្ញុំស្គាល់បន្ទប់ស៊ីជុងយីស្រាប់គ្រាន់តែលបចូលទៅហៅគាត់មកក្រៅថ្នាស់ប្តូរអោអវគ្នាទៅជាការស្រេច ។ លុះព្រលឹមឡើងបងធ្វើជាស្រែកថ្ងូរថាឈឺបំពង់កទៅណា ! ចាំដល់លោកគ្រូប៉ាយចង់សម្លាប់សឹមបងនិយាយវោះសា ។

ស៊ីជុងធានត្រេកអរជានេកសរសើរថា:

-ទីន តុន, នាងឆ្លាតណាស់ហ្ន៎ ! ចេះគិតឃើញសព្វគ្រប់តែម្តង

ទីនតុនបញ្ជាក់ទៀត:

-បងកុំភ្លេចឲ្យសោះណា៎ ! នៅតាមផ្លូវកុំនិយាយរកអ្នកណា, ជាពិសេសត្រូវប្រយ័ត្នជាមួយលោកម្ចាស់ភូមិឲ្យមែនទែន ។ ម៉្យាងទៀតពួកលោកគ្រូប៉ាយវាឥតវៃណាស់ដែរ, តែបងប្រហែសខ្លួនគេសឹងប្តូចាប់ថ្នាក់បានខូចការធំ, ជួយលោកម្ចាស់ភូមិឋានសិនសូមិនកើតទេ ។

ស៊ីវធានឆក់ក្បាល :

-ខ្ញុំជឿហើយ, ចាំហើយ ! ទោះគេសម្លាប់ខ្ញុំក៏ខ្ញុំមិនហ៊ានមាត់ប៉ះពាល់ដែរ ។ ទៀងមើន !

រំពេចនោះឮសូរខ្លាក ! ទ្វារបន្ទប់បើកឡើងលេចនារីម្នាក់ចូលមកស្រែកប្រាប់ថា:

-លោកនាយក្រុមកុំចាញ់ល្បែងគេ !

បន្ទប់ធំនឹតមើលមិនឮស៊ីវធានតាបស្គាល់តាយជានក៏សួរទៅវិញ:

-តាយជាន, នាងថា...កុំចាញ់ល្បែងនរណា ?

តាយជានឆ្លើយ:

-ខ្ញុំស្តាប់ឮអស់ហើយ, អ្នកនាងឥតមានមែនមនុស្សល្អទេ ។ នាងចង់... ចង់ល្បែងលោ
ប្រុសឲ្យទៅស្តាប់ដំនួសគេ ដើម្បីនាងជួបបងប្អូននាងសម្បុរសម្លួយជីវិតនោះណា !

-មិនមែនទេ, អ្នកនាងឥតឆ្លាប់ឲ្យខ្ញុំទៅជួយយកការលោកម្ចាស់ស៊ីវធានលោកស្រីតើ !

តាយជានពោលចាំងក្រហល់ក្រហាយ:

-សុំលោកប្រុសគិតឲ្យស្រួលបួលសិន, ពួកគេមិនមែនល្អនឹងលោកប្រុសទេ ។

ឥតគុងធ្វើតពោលចាំងសោះកក្រោះថា :

-ល្អហើយនាងស្រី ! តើដើមនាងជាប់បើលោកប្រុស, ឥឡូវចង់ប៉ប៉ែកបំបាក់គេពីលោកប្រុស
ដើម្បីយកកំរៃឬ ?

នាងងាកទៅប្រាប់ស៊ីវធានថា :

-បងធានកុំវេរស្តាប់ស្តីតាបប៉ោកនេះអី, បងទៅចាជួបសណ្តាំពីនាយត្រួតត្រួតូលឈឺនមក
តែកុំនិយាយរឿងយើងប្រាប់គេណា ! ទៅយកជួបមក ! ខ្ញុំចាំបងនាងត្រៀម ។

-នាងយកជួបសណ្តាំធ្វើអី ?

-បងគង់តែជឿនេ.. ទៅយកភ្លាមឡើង !

ស៊ីវធានឆក់ក្បាលយល់ព្រម ហើយប្រាន់បង្អួតលោតចេញទៅក្រៅបាត់ ។ ឥតគុងសើ
ខ្ទឹបរោយពេញចិត្តអ្វីម្នាក់ឯងថា:

-យើស ! មីចង្រៃនេះចិត្តល្អណាស់តើ !

តាយជានក្រាក់ត្រឹតស្រែកយំរែកខ្ទរត់ទៅក្រៅតែឥតគុងហ៊ាសជាង, ស្តុះវិលទៅលើកដៃចាំ

ពីរេះខ្លួនឯងដាំដំរ, នាងក្រមុំតាយជាន់ស្រែស់ស្លាវដង់ដួលស្លាប់មួយរំពេច ។

ទីឆ្នូតរៀបនឹងលោតចេញទៅ, ខ្លួចឆ្កែឃើញអ្វីមួយ ក៏ត្រឡប់មកវិញចាប់កន្ត្រាក់អាវតាយជានវែកខ្លួចខ្លី ហើយលើកសពនាងវាក់លើត្រែស៊ីផ្ទាន់ពាក្យភ្លួយដណ្តប់ឲ្យជិត ។ ទីឆ្នូតមានបណ្តឹងអង្រួកចង់ឲ្យក្រុមឈានលួយើញសភាពការណ៍នេះ យល់ដុំយស្រឡះថា តាយជានត្រូវស៊ីផ្ទាននាយក្រុមរំលោភលើភរិយា ហើយនាងរើបរៃតាល់តែលោកនាយក្រុមអត់មិនបានវាយស្លាប់ទៅ ។ មិនតែប៉ុណ្ណោះនាយក្រុមល្មោភកាមគុណគេចង្ហុនត់ចាត់មិនឲ្យពលសេនាឃើញមុខទៀត ។

នាងយល់ថាធ្វើបែបនេះ ជំណើរការរៀបចំហេតុសមផលគ្មាននណាស្រាវជ្រាវរកដើមកំណើតឡើយ ។ ទីឆ្នូតរៀបចំស្រួលបួលគេញចិត្តហើយទើបតំរង់ទៅរំដំាស៊ីផ្ទានខាងក្រៅផ្ទះ ។ បួយសន្ទុះមាណពដើរចេញមកក្រាប់ថា :

-ខ្ញុំយកជួបបានហើយ ។

ទីឆ្នូតងក់ក្បាលសរសើរថា : ល្អ!

អ្នកគាំងពីរបបួលគ្នារត់ទៅមាត់ស្ទឹងឡើងជិះទូកបន្តដំណើរទៅ ។ ទីឆ្នូតរំអុំទូកបណ្តោយចឹកប្រហែលបីបួនយោជន៍ទើបឡើងច្រាំងត្រង់កន្លែងមានសេះពីរបង្គរក្រាមដើមឈើស្រាប់ ។

នាងពោលថា:

-យើងជិះសេះតទៅមុខទៀត !

ស៊ីផ្ទានសរសើរ:

-នាងចាត់ការល្អិតល្អន់ណាស់ហ្ន៎ ! សូម្បីតែយានជំនិះត្រប់ប្រកេកក៏នាងមិនភ្លេចដែរ ។

ទីឆ្នូតទឹងមុខក្រហមងាឹងមួយរំពេច :

- ល្អិតល្អន់យ៉ាងម្ដេច ? សេះនេះជារបស់លោកតាស្រាប់ហើយខ្ញុំយល់ថាមង់មិនប្រកែកទើបនាំវាមកទុកមុនណា !

ស៊ីផ្ទានឆ្លើយដែរ ហេតុអីនាងទឹងភ្លាមៗដូច្នេះ, តែនាយមិនចង់ស្តីច្រើនក៏លោតផែលលើខ្នងសេះចេញដំណើរជាមួយនាងទៅ ។

ប្រហែលយាមបួនគេទៅដល់ទីប្រជុំជន ហើយលោតចុះពីខ្នងសេះដើរចូលក្នុងភូមិសំដៅផ្ទះ

Khmer Story Lovers

សំណាក់ ។ ទីធនុធរោលតិចៗ:

-លោកម្ចាស់ស៊ីនិធរលោកស្រី ព្រមចាំធស៊ីផុធយើងកុងធបន្ទប់ធំខាធលិចបង្គស់ ។

ស៊ីផធានសួរ:

-យ៉ ! តេធាក់កុងធបន្ទប់តែមួយយ៉ាធនេះតិចរលោកម្ចាស់ស៊ីឬលោកស្រីក្បាក់ទៅ ?

-ហ៊ឹះ ! ឥពុកម្តាយអីគិតតែកិត្តិយសផ្ទាល់សុខចិត្តដេកឃ្លាលកូនប្រុសខ្ចាចកូនតែចាក់ឥតមានកូន
ណាប្រគល់ឲ្យក្រុមភ្ញៀវកកក ។ គាត់គ្មានទឹកដមល់ពុកពុះកូនទេ. ឥពុកម្តាយរបៀបនេះកម្រមា
ណាស់ ! កូនធ៊ាកពតគុនតេមិនប្រទះឡើយ ។

សំដីនេះមានន័យថាធានមិនពេញចិត្តនឹងប្តីប្រពន្ធស៊ីឈ្នះទេ ។ ស៊ីផធានមិនដឹងធ្វើយថាម៉េច
ក៏សួរនាធទៀត:

-យើងគិតធ្វើម៉េចទៅ ?

-បងអុជធូបសណ្តំនេះយកទៅសិកតាមបង្គំបបន្ទប់គាត់ រើម្បីបង្ហុយផ្សែងទៅកុងនោះ
កាលណាធូបនេះអស់. លោកម្ចាស់ភូមិស៊ីនិតរីយាឲ្យាស់ជាសន្ធប់លែងធឹងស្ពឹហើយ ។ ពេលនោ
បងប្រាធបង្គំបថ្នមៗចូលទៅនាំស្ទឹងធុងយើងមក ! បងមានកុងវ៉ាឡាខ្ពង់ខ្ពស់ស្រាប់ ត្រូវចេះសម្រាលខ្ល
ស្មោះតាមបងកុំឲ្យនរណាឮ, ចំណែកខ្ញុំ ខ្ញុំនៅចាំបងឯក្រៅ ។

ស៊ីផធានធ៊ាកក្បាល !

- អ៊ីចឹងហើយ, ឱកយើញហើយ ! លោកនាយត្រួតឈិនចាប់សិស្សភ្ញៀវកកកបានមួយហ្វូ
ដោយសារធូបសណ្តំនេះដែរតើ !

ទីធនុធធ៊ាកក្បាល:

- នេះជាវត្តិព្ធដ៏អន់របស់ក្រុមបង, តែប្រហែលតូកែសត្តិសិទ្ធិណាស់, បើគុំនោះទេតូ
បងមិនឆាយចាប់សិស្សភ្ញៀវកកកបានឡើយ ព្រោះគេមិនមែនអន់ណាស់ណាទេ ។ បងប្រយ័ត្
ខ្លួនឲ្យមែនទែនណា ! កុំឲ្យឮសម្លេងអ្វីសោះ ព្រោះប្តីប្រពន្ធលោកម្ចាស់ស៊ីមិនមែនអន់ជាងសិស្ស
កកកទេ ។.

ស៊ីផធានធ៊ាកក្បាលយល់ស្រប ហើយគុសភ្លើងអុជធូបភ្លាម ។ គ្រាន់តែធុំក្លិនផ្សែងបន្តិ
នាយបធ៌ងធឹងមុខទៅហើយ , ខោះនៅកណ្តាលវាលក៏ដោយ ។ នាយក្បាក់ត្រើតសួរ :

- យី ធូបនេះអាចធ្វើឲ្យមនុស្សស្លាប់ទេអីក ?

ទីឆតុងញញឹម :

- បុះកាលពួកបងទៅចាប់សិស្សភ្នំចឹកកក , បងមានឃើញមួយណាស្លាប់ទេ ?

- អើគ្មានទេ ! នាងចាំខ្ញុំត្រង់ណោះបុះ ។

មាណពដើរជិតរបងទន្លុំដើងលោតផ្លោតទម្លាក់ខ្លួនស្រាលស្ទើរតតឮសូរស៊ើឮអ្វីបន្តិចសោះ ហើយដើរលបៗទៅដល់បន្ទប់ទាងលិចបង្អួលផ្ទៀងត្រចៀកស្តាប់ឮសូរបេរ៉ើមមនុស្សបីនាក់ពុកម៉ែ លងលៃយ៉ាងស្តាប់ស្តួស ។ នាយលិទ្ធចឹកមាត់លាបក្រវាសបង្អួចរួចខ្នេះខ្នែងមួយសឹកសរសៃធូបចូលទៅក្នុងបន្ទប់ ។ មួយភ្លែតសោះធូបសណ្តំនេះអស់រលីង, នាយសម្ងំស្ងៀមរង់ចាំស្តាប់ឥតឮសម្លេងអ្វីសោះ ទើបចំរើនកម្លាំងកាច់ទ្រុកបង្អួចរបើកខ្លាក, នាយលោតផ្លោតចូលក្នុងបន្ទប់ ។

ពេលនោះមេឃក្រហមត្រឿងជិតភ្លឺហើយ នាយបើញត្រែថ្នាក់ទទឹមគ្នា, ប្តីប្រពន្ធស៊ីឈ្ងឹងដេកលើត្រែខាងជើង, ស៊ីផុងយីដេកម្នាក់ឯងលើត្រែខាងលួង ។ ក្នុងពេលថាមួយមោះនាយបង់តែងងឹតមុខងួលដោយសារក្លិនធូបសណ្តំ ម្ល៉ោះហើយនាយប្រញាប់ខ្ជប់ច្រមុះបិទដង្ហើមសុះទៅលើកស៊ីផុងយីស្នួយពីលើត្រែសៅតចេញតាមបង្អួចភ្លាម, ហើយលោតចេញក្រៅរបងរកទីឆតុង ។

ទីឆតុងរង់ចាំយ៉ាងស្ងៀមស្ងាត់ ។ លុះឃើញស៊ីផងាងបីស៊ីផុងយីមកដល់ខាងស្តាំងអរកខ្ចិបកខ្ចុបថា:

- បងមកហើយឬ ? ឆាប់តត់ឲ្យឆ្ងាយប្រយ័ត្នលោកគ្រូចាំយក្បាក់ចាន់ ។

ស៊ីផងានលីស៊ីផុងយីរត់ទៅប្រហែលបួនដប់ក្បាមទើបឈប់ ។ ទីឆតុងគោលក្លាម:

- បងងានដោះខោអាវប្តូរនឹងគាត់ភ្លាមឡើង ! អ្វីៗទៅក្នុងថង់អាវក៏ប្តូរគ្នាដែរ ។

ស៊ីផងានលូកយកប្រអប់តុក្កតាឈើជាអំណោយតាពៃ, និងថ្នាកស្តាំចាំរ៉ាប់ស្តួរថា:

- វត្តចាំងនេះឲ្យ . . ឲ្យគេដែរឬ ?

- ឲ្យគាត់ចាំងអស់ចុះ . ខុកទៅនឹងខ្លួនបងចាំឲ្យគេសង្ស័យ ... នៃលឿនឡើង ! ខ្ញុំទៅយាមល្បាតខាងណោះឲ្យ ។

ស៊ីផងានដើរចាំទីឆតុងទៅផុត ទើបដោះខោអាវប្តូរជាមួយផុងយី តាំងពីខោទ្រនាប់រហូតដល់អាវក្រៅនិងស្បែកជើង ។ លុះស្រេចហើយនាយស្រែកហៅ:

– ទីឥតុងៗមកវិញចុះ , ខ្ញុំផ្ទាស់ប្តូរហើយ ។

ទីឥតុងរត់ហោមកពោលបញ្ជាក់ជាពុំឆ្ងល់ក្រាយៈ

ជីវិតលោកប្តាស់ភ្លេចនិងលោកស្រីស្ងួតក្នុងកណ្តាប់ដៃបង, ពិសេសត្រង់បងក្លើសបម្រុងនូវមាសជាមាណពឥតក្តាល :

–ខ្ញុំនឹងរំបំពេញការណីយកិច្ចនេះទាល់តែសំរេច ។

បន្ទាប់ពីនោះទីឥតុងលួតយកកូនប្រុសមួយតួចមើតតំរេខ្លះផ្ទាំមេរៀបនិយាយមកប្រាប់ថា :

–បងធើបមុខស្លៀងមើល ?

នាងលាបថ្នាំលើបំពង់កមាណពត្រមាំងប្រាប់ថែមទៀត :

– ដល់ភ្លឺបងផ្លូតថ្នាំនេះចេញកុំឲ្យគេមើលឃើញ ប្រយ័ត្នបែកការណ៍ណា ! ចាប់តាំងអ្នកទៅឈឺបន្តិចហើយ , សូមបងចេះអត់ទ្រាំខ្លះទើបសម្រេចការយើង ។

ស៊ីផជានឥតក្តាល :

– មិនអីទេ , សុំនាងកុំព្រួយ ។

នាយឃើញស៊ីផុងយីបំរះខ្លីក ។ ក៏ប្រញាប់ពោលថា :

– ទីឥៗ តុង។... ខ្ញុំទៅហើយណា !

ទីឥតុងលើកដៃឥឿនថែម :

– ទៅចុះ ! ទៅចុះ !

ស៊ីផជានចោះដំហានវែង។តម្រង់ផ្លុះសំណាក់វិញ ។ បានប្រហែលប្រាំម៉ែត្រនាយឈប់មួយស្របក់ងាកមើលក្រោយឃើញស៊ីផុងយីអង្គុយលើស្មៅហាក់កំពុងនិយាយជាមួយទីឥតុងតិច។ ។ ភ្លាមនោះនាយឮទីឥតុងសើចខឹក។ យ៉ាងសប្បាយ....

មាណពក្តុកក្តួលក្នុងខ្លួនឮសម្លេងមួយខ្សឹបប្រាប់ថា អំណើះតទៅនាយខានហួសទីឥតុងទៀតហើយ ។

នាយឈរភេាមួយសន្ទុះទើបលោតផ្លោះបងទៅប្រាន់ចង្កឹចបន្តុំអម្បាញ់មិញចូលផ្ទុក ។ កូនធ្លាទៅតួលពេញបន្តុំ, នាយបើកបង្កឹចចំហឲ្យខ្យល់ផាត់ទៅក្រៅហើយត្រចៀកនាយឮហាក់មានសម្លេងជើងសេះរណ្តំគ្នាល្មើយ។, នាយជំនឹងថាច្បាស់ជាទីឥតុងឡើងជិះសេះជាមួយស៊ីផុងយីទៅកន្លែងសុខ

Khmer Story Lovers

ហើយ ។ ទ័ពតុងនាំគេទៅណា ? នាងសប្បាយចិត្តយ៉ាងណា ? នាយនឹកថា :

- យើងសួរទៅណាស់, ទ័ពតុងទៅជាមួយយើងមិនដែលបានសប្បាយម្តងណាសោះ ។

មាណពឈរមាត់បង្អួចមួយសន្ទុះធំទាល់តែឈឺបំពង់កបន្តិចៗទើបទាញបង្អួចបិទជិតហើយចូល ៗ ក្រលុំភួយបិទភ្នែកសម្ងំស្តាប់ឈឹង ។

ទ័ពតុងមានថ្នាំសក្តិសិទ្ធមែន, មិនបានកន្ទុះមោងផង, បំពង់កនាយឈឺតែតូចតាចឡើងៗ . . . នាយយកដៃស្ទាបតែបំពង់កក្តៅស្ទើរលាក ហើយកំពង់កនេះហើមយ៉ាងធំ ។ លុះភ្លឺស្រាង ។ នាយលួចផ្លូតថ្នាំមេ្យាចេញស្អាតព័ត៌ពង់ក ហើយស្រែកថ្ងូរហ៊ុះ តាមស្តាប់ដែលទ័ពតុងប្រាប់ដើម្បីឲ្យប្តីប្រពន្ធស៊ីឈឺងយកចិត្តទុកដាក់នឹងបំពង់កភ្ញៀចក្ញិនឆ្ងបសណ្តាំ ។

មែន ! ភ្លាមនោះស៊ីឈឺងក្រាក់ព្រឺពោះយ៉ាងសាហាវមួងថ្ងូរហ៊ាយៗ :

-តើតអីហ្នឹង ?

សម្ងួនគាត់ដូចជាខឹង, តែវុនយូស្តុះក្រោកភ្លែកសួរយ៉ាងខន់ភ្ញាក់ :

-កូនយីតើតអី, កូនមិនស្រួលខ្លួនឬ ?

អ្នកស្រីមិនដឹងថាជាម្តេចទេ, គាត់ក្រោកដើរមកទាញភួយចេញមើលស៊ីឈឺងភ្លាមឃើញមុខនាយក្រហមងាំង, បំពង់កហើមស្ទុះក៏ភ័យខ្លាត់ស្រែកហៅ :

-ពុកអ៊ុ...ហ...មកមើលឆាប់ឡើង !

ស៊ីឈឺងឮកាយហៅយ៉ាងក្តីភ័តភ័យក៏ប្រញាប់ស្ទុះមកដល់គ្រែកូនមើលបំពង់កហើយតោល :

-ប្រហែលជាបួសឬតើតគិសអីទេដឹង ? ត្រូវប្រញាប់ព្យាបាលទើបមិនភ្លាយ ។

គាត់សួរស៊ីឈឺង :

-កូនឈឺណាស់ទៅឬ ?

មាណពថ្ងូរហ៊ុះមិនត្រមធ្លើយសោះ, តែក្នុងចិត្តនឹកថា :

- ខ្ញុំពង់ជួយជីវិតលោកទាំងប្តីទាំងប្រពន្ធ ទើបសុខចិត្តធ្វើតាមទ័ពតុងបំបិទភ្នែកលោក, ខ្ញុំឈឺប៉ុណ្ណឹងលោកពិបាកចិត្ត, លោកព្រួយម្ល៉ឹងទៅហើយហ្ន៎ ! ហ៊ឺ ! ស៊ីឈឺងយីប្រព្រឹត្តអំពើអាក្រក់យ៉ាងណាក៏លោកនៅតែស្រឡាញ់គេដែរ, ចំណែករូបខ្ញុំឥតមានអ្នកណាស្រឡាញ់ទេ ។

មាណពនឹកស្រណោះខ្លួនពេកក៏ហូរទឹកភ្នែកហាម ។ ស៊ីឈឺងនិងវុនយូភ័យស្ងើចភ្នែក

ដោយសើចដាក់ថាកូនប្រុសឈឺខ្លាំងណាស់ទើបហៅមាត់និយាយមិនតើត, ចាន់ត្រមង្គើទឹកភ្នែក ។
ស៊ីឈីងលួងលោមភ្លាម :

- ពុកទៅកែគ្រូពេទ្យមកមើលជម្ងឺកូនណា ។

រុនយូដូតទឹកភ្នែកឲ្យកូនបណ្តើរពោលបណ្តើរ :

- ភ្លាមនេះដាច់ប្រយោលគ្មានពេទ្យហ្នឹងណែកែមើលទេ, យើងគិតត្រឡប់ទៅយ៉ាងម្តេចអញ្ជើញលោកគ្រូតែមកមើលល្អ ?

ស៊ីឈីងគ្រវីក្បាល:

- ទេ, កុំធ្វើរំពឹង ។ ខ្មែយនាំឲ្យថ្មាយវាន់ជាងសង្ឃ . ទីពីរនាំឲ្យតែហែស៊ីរមើលងាយ ។

គិតស៊ីឈីងដឹងថា គ្រូមណាន់លួមិនចេញចិត្តនឹងកូនប្រុសកំសាកនេះទេ, ហើយគ្រូមណាន់លួមិនសូវត្រឹមត្រូវនឹងគ្រែនេះគ្រឿតទុកាសជាក់ថ្នាំពុលថ្នាំពិសសម្លាប់កូនកាត់ទៅ រឹតតែបើកាយវិការម៉ោះរហើយគាត់ប្រកែកនឹងកិរិយារហើយតត់ទៅក្រៅភ្លាម ។

រុនយូចាក់ទឹកតែក្តៅមួយពែងហុចឲ្យកូនដឹក តែថ្នាំទឹងកុនកាចសាហាវអស្ចារ្យធ្វើឲ្យហើមពាំងកូនពាំងក្រៅ, សូម្បីលេបទឹកតែក៏មុនបានផង ។

មិនយូរប៉ុន្មានស៊ីឈីងនាំគ្រូពេទ្យចំណាស់ម្នាក់មកដល់ គ្រូពេទ្យពិនិត្យកែសុាបស្លឹងពីពេលរួចពាល់ហើយគ្រវាត់តែគ្រូក្បាលតែកាត់:

-ជម្ងឺដែលពិបាកព្យាបាលលើសជម្ងឺផងពាំងតួតីជម្ងឺត្រង់បំពង់កនេះឯង, ព្រោះមិនអាចដឹកថ្នាំបាន, ពិបាកព្យាបាលណាស់ !

ស៊ីឈីងពោល:

-លោកគ្រូ, កូននេះទើបនឹងលើម្តុំ អាចប្រើថ្នាំណាបប្រហែលបានដែរ ?

គ្រូពេទ្យធ្វើក្បាលងឺងើ:

- ក្មួយប្រុសនេអាចសំណាងល្អណាស់ទើបជួបខ្ញុំ ។ ប្រហែលមានសង្ឃឹមខ្លះ , តែមិនអាចឲ្យស្រួកហើមភ្លាម។ ទេណា !

ស៊ីឈីងនិងរុនយូងឿងាកូនប្រុសចៀសមុខពីមរណៈហើយ ក៏ធូរក្រូចបន្តិច សុំលោកគ្រូរកមើលសរសរសំបុត្រទៅវិញថ្នាំយ៉ាងប្រញាប់ ។ គ្រូពេទ្យសញ្ញឹងគិតបន្តិចសរសេរឈ្មោះថ្នាំហុច

ឲ្យស៊ីឈ័ង ។ ស្គាល់ប្អាំនេះខ្លះលើត្រូវសានោះដឹងថាជាថ្នាំត្រូវគាប់សម្រាប់រំលាយពិស , ទើបពោលពាក្យថ្លែងអំណរគុណ និងជូនទ្រាក់ទ្រាំដើម្បីឆាប់ជាឆាប់ឆ្ងាន់ ព្រមទាំងជូនដំណើរគាត់ទៅវិញ, ស៊ីឈ័ងទិញថ្នាំបណ្តាយ ។

ពេលនេះក្រមភ្នំទឹកកកខ្លួលដំណឹងស៊ីជុនយើមានភេតាព្យាធិ, ប៉ាយវាន់ជានខ្វាចប្តីប្រពន្ធស៊ីឈ័ងប្រើកលល្បិចដើម្បីរំលោះកូនតីថ្លើជាមកសាកសួរដឹង តែការពិតគាត់មកពិនិត្យផ្តាល់ដើម្បីដឹងច្បាស់ថានាយឈឺមែនឬមិនមែន ។ លុះឃើញបំពង់កមាណពហើមស្ពុនដឹងឃើញវុនយូតំយសស្ងាក់សស្តើតគាត់ត្រេកអរក្នុងចិត្តនឹកថា :

-អាចង្រៃហ្នឹងឯលួចគេក, សាហាវគេក, បើនាំវាទៅដល់ភ្នំទឹកកកទើបស្លាប់ដួចជាងាយណាស់, ឥឡូវវាឆេតុក្ខវេទនាដូច្នេះក៏ម្យ៉ាងដែរ ។ អាហ្នឹងហើយគេហៅថាកម្មតៀវគេតាមមកទាន់ !

ប៉ាយវ៉ាន់ជានជាអ្នកក្លាហានដ៏ល្អ ទោះសម្បុយចិត្តក៏មិនហ៊ានបង្ហាញទឹកមុខរីករាយចំពោះមុខអ្នកមានទុក្ខដែរ ។ ម៉ិនតែប៉ុណ្ណោះគាត់ជួយពោលពាក្យលួងលោមវុនយូទៀតផង ។

ស៊ីឈីង ទិញថ្នាំមកដាំបញ្ចុកកូនហើយពោលភ្លាម :

-នៅខាងក្រៅមានរនេះបួយរលីចាំជារស្រេច ។ ផ្ទុយយីជាកូនប្រុសត្រូវតាំងចិត្តក្លាហានកុំឲ្យគេចកដំណើរដោយសារដើម្បីបច្ចុប្បន្នេះ ។

វុនយូតវិញ :

-កូនឈឺប៉ុណ្ណឹងហើយនៅបង្ខំឲ្យវាធ្វើដំណើរទៀតប្រយ័ត្ន . ដើម្បីតែឆ្លង់ណា !

- មិនកើតទេ, អ្នកត្រូវដឹងថាសេនាបញ្ជាបណ្តាំបានចេញដំណើរទៅគាត់ភ្នំទឹកកកមុនយើងហើយ, ហេតុនេះប៉ាយវាន់ជានត្រូវទៅឲ្យដល់ភ្នំទឹកកកមុន ក្រែងលោកអំប៉ាយបានប្រយុទ្ធជាមួយសេនាពាំងពីមុនយើងទៅជួយ គាត់រឹតតែទាំងខ្វេខ្វើឆណា !

វុនយូចាស់ច្រកក៏ដក់ក្បាលឆ្លើយចាំស,ចាំស ! ហើយដាក់ទៅច្រាប់ស៊ីឈានៈ

-កូនប្រុស, ចាំម៉ែជួយស្ងៀតពាក់ឲ្យ ។

ប៉ាយវាន់ជានឃើញស៊ីឈ័ងបង្ខំកូនឲ្យបន្តដំណើរចាំឆ្ងល់ ទើបនឹកស្ទើចសរសើរទឹកចិត្តក្លាហាន មុះមុតនៃឪស់ភូមិវ៉ាន់ស៊ានស្ទិ ។ រីឯវុនយូស្គាល់ចិត្តថ្លើមស្វាឆ្ងីតាំងពីដំបូង, គាត់យល់ថាស្ថានការណ៍ក្លែងដល់ថ្នាក់នេះហើយស៊ីឈ័ងពិតជាមិនទាំកូនតែឡើយ ។ ប៉ើសេនាបញ្ជាមរណៈទៅគាត់ភ្នំ

ទឹកភក្តដូចនឹងប៉ាយប៉ាយចិត្តខ្លាំងដូចពាក្យអីតស្រែសារ, តាចាស់ពិតជាមិនត្រូវចន្លួលផ្លាកស្តាប់ទេ ។ ពេលនោះឆាកប្រយុទ្ធនឹងកើតមានឡើងរវាងតាតំនិងបាឆ្នាសានលើសែជាជាប់ខាត ។

ស៊ីឈឺឆបនឹងរួតរះដំណើរដើម្បីទៅដល់ភ្នំទឹកភក្តមុនសេនាបញ្ជាមណៈ,បើជួយដោះពុត្តកុរះក្រុមភ្នំទឹកភក្ត ហើយតាត់ត្រូវអស់សង្ឃឹមក្នុងទីប្រយុទ្ធតាត់ពេចបាត់ពុកជាការធម្មតានៃពិតពគុន គឺជួចបានលុបលាងកំហុសរបស់កូនដែរ ។

ប្រសិនបើតាត់រួមក្នុងប្រយុទ្ធឈ្នះសេនាចាំងពីរវិញ, ដំណឹងនេះនឹងលេចល្បីខ្លាយពេញពិតពគុន ថាក្រុមភ្នំទឹកភក្តនឹងម្ចាស់ភូមិចាន់សុី មានជ័យជំនះលើសេនាបញ្ជាមណៈ ។ ដោយនោះកំហុសរបស់ស៊ីជុងយីចាំងប៉ុន្មានក្រូវលប់រលាយដោយឯកឯកឹ ឬយ៉ាងហោចណាស់ក៏ក្រូវបន្ទុបន្ទុយច្រើនដែរ ។

នុនយូពិចារណាថា កាលនៅតំបន់ក្រុមឈានលួតាត់ឃើញស្ថានភាពគិនលីសែពិតជាមិនងាយឈ្នះមែន ។ ប៉ុន្តែមនុស្សយើងនោះមានវិជ្ជាខ្ពង់ខ្ពស់យ៉ាងណាក៏ភ្លាត់ស្នៀតម្តងៗដែរ, លោតែសំណាងមានក្រួសារគាត់អាចមូលត្រកូលឡើងវិញ រស់នៅដោយសុខសាន្ត ។ ដោយមានសង្ឃឹមយ៉ាងនេះទើបពីនាក់ប្តីប្រពន្ធអន់ព្រួយតាមផ្លូវ ។ អ្នកទាំងពីរយល់ចិត្តគ្នាណាស់, មិនចាំបាច់និយាយច្រើនក៏នុនយូស្គាល់គោលបំណងរបស់ស្វាមីក្នុងការនាំកូនប្រុសទៅកាន់ភ្នំទឹកភក្តដែរ ។ គាត់ជានារីគ្មានល្ប៉ិលល្បាញដូចស្វាមី ទោះស្រឡាញ់កូនយ៉ាងណាក៏មិនហ៊ានពោលជំទាស់ ។

ស៊ីជងនិងស៊ីជុងយីដូចគ្នាបេះបិទ, ពេលនេះនាយស្នៀកពាក់ខោអាវល្អប្រណិតបានក្លាយជាបុរសកម្ពោះមួយរូបដ៏ស្រស់សង្ហា ។ មាណពដែកស្នៀមក្នុងរបេះឥតបេញស្តីមួយម៉ាត់ ឥតទ្វើឲ្យស៊ីឈឺឥឬ ប៉ាយអាន់ជានសង្ឃឹយបន្តិចណាឡើយ ។ ចំពោះរឿងបាត់នាងនីដ៏ងគុនចាំក្រូវប្តីប្រពន្ធស៊ីឈឺងឥតដេញដោលឬកេហេតុផលអ្វីទេ, ម៉្លាងទៀតកាត់បែរបញ្ចាតពីកូនយូរឆ្ងាំហើយទោះ មាណពមានការយល់ការខុសប្លែកពីដើមយ៉ាងណាក៏គាត់ឥតចាប់ភ្ញាក់ទៀត ។

អ្នកទាំងអស់ទំស្រុតដំណើរទៅកាន់ភ្នំទឹកភក្តខ្លាចតាស៊ីជានឹងលីសែទៅដល់មុន, ម្ចាស់ហើយគេមិនហ៊ានឈប់សំរាកយូរទេ ។

លុះទៅដល់ស្រុកហ៊ួណាន បំពង់កស៊ីជានជាត់ហើម ចាត់លឺតែនាយទៅទ្វើគេនិយាយមិនរួចគ្រាន់តែងក់ក្បាលអ៊ីៗមួងៗប៉ុណ្ណោះ ។ ស៊ីឈឺងអកេទ្យហ្មកពិនិត្យច្រើនលើក តែមិនឃើញ

ចាមការអ្វីសោះ រាវតែតែក្តីឲ្យគាត់តបប្រមល់ខ្វាយខ្វល់ទៅឡើងនិងឲ្យអ្នកស្រីវុនយូសម្រក់ទឹកភ្នែកលើសដើមប៉ុណ្ណោះ ។

ច្រើនថ្ងៃកន្លងមកទៀត គេបួលដល់ដំបន់ភ្នំទឹកកក ។ សិស្សរួមគ្រូបេស់ចាំយកាន់ជានដើរតាមផ្លូវគាត់ចាំនយប់ចាំនថ្ងៃដើម្បីដល់ទីកន្លែងឆាប់រហ័សត្រមចាំនឹកថា :

-ចាផសានឆិលីសៀលឿនយ៉ាងណាក៏មិនស្គាល់ផ្លូវគាត់ ហើយមិនទៅដល់ទីគាំងមុនដែរ ។

គេទៅជិតដល់ភ្នំទឹកកកណាស់ តែតែរកយសប្បាយណាស់, ផ្ទុយទៅវិញប្តីប្រពន្ធស៊ីឈឺងស្រួតឡើងៗ នឹកស្រមៃដល់ពេលដួបមុខប៉ាយជាយមិនដឹងតាចាស់នាយក្រុម ទទួលខ្លួនតាមបៀបណា ។ បើគាត់ខឹងច្រឡោតប្រហារស៊ីផ្ទុងយើចោលភ្លាមទៅ ហើយសេនាបញ្ជាមរណៈមកដល់ស្មមតើប្តីប្រពន្ធត្រូវគាន់យកអាកប្បកិរិយាយ៉ាងណា? គិតចុះគិតឡើងគាត់រាវតែតែពិបាកចិត្ត រឹតតែមួហ្មងតឹងទៅមុខបន្តិចក៏មិនបាន ទៅក្រោយពោកក៏មិនកើត ។ ពីរនាក់ប្តីប្រពន្ធពិគ្រោះគ្នាច្រើនលើកច្រើនសាទៅតែជំពាក់ដោះស្រាយមិនរួច, ង៉ោះហើយគេនៅស្ងៀមស្ងាត់រង់ចាំទទួលវាសនាតាមយថាកម្ម គិតថាចាំកាលណា សឹមកាលណោះទៅ ។

ពីរបីថ្ងៃក្រោយគេមកដល់ផ្លូវភ្នំរជិបរជុបគាន់តែខ្ពស់ឡើងៗ ។ ពេលថ្ងៃត្រង់គេទៅដល់ជំណាក់មួយ មានផ្ទះឈើនិងមួស្បីមួយផ្ទះ ។ ចាំយកាន់ជានសាកសួរអ្នកយាមផ្ទះបានដំណឹងថាក្នុងប៉ុន្មានថ្ងៃក្រោយនេះគ្មានភ្ញៀវចំណែកមកកាន់ភ្នំទឹកកកទេ ។ អ្នកទាល់គ្នាដកដង្ហើមយូរធូរទ្រូងដូចទើបយកដុំថ្មចន្ទន់ចេញឬ ។ ភក្រ្តីនោះគេនាំគ្នាស្នាក់ក្នុងផ្ទះឈើតូច ។

ស្អែកឡើងគេផ្ញើរដំនិះខុកត្រង់នោះហើយបន្តដំណើរផ្ទាល់ដើងឡើងភ្នំទឹកកក, ព្រោះចាប់ពីត្រង់នោះទៅផ្លូវពិបាកណាស់ដិះសេះក៏មិនកើតដែរ ។ សិស្សភ្នំទឹកកកដើរអុចគាំផ្លូវ. ខ្លែងកាន់តែខ្ពស់ផ្លូវគាន់តែពិបាកត្រូវតោងត្រូវវរយ៉ាងលំបាក ។ ប្រហែលជាងមួយមោងគេទៅដល់ដំបន់ទឹកកកស្ងាត់ឈឹងលើយជួបផ្ទាំងសំពត់ស ។ កន្លែងនេះអិលណាស់តែគេបេះសម្រាលខ្លួនគ្រប់គ្នាទើបរំអិលខ្លួនលើទឹកកកបានដោយស្រួល, ។ ស៊ីផងានតាមប្តីប្រពន្ធស៊ីឈឺរប្រកិតឥតឃ្លាតមួយជំហានឡើយ ។

ស៊ីឈឺងនិងវុនយូឃើញស៊ីផងានតស៊ូនឿយហ័ស ហើយឥតដកដង្ហើមញាប់សោះក៏នឹកចម្លែកក្នុងចិត្តថា:

-ក្លិនខេមានកម៉ាង់ពាក្យគ្រាន់បើ មិនចាញ់ផង់ទេ

ប៉ុន្តែភ្លាមនោះភាន់ខឹងដល់ពេលផ្ទួបប្រុងប៉ាយដាយ ក៏ប្រែចិត្តមុខជាស្រួតស្រែកតភ្លាម ។

ឧក្តដ្ឋ ៣៣

ចិបត្តិនៅភ្នំចិចកក

គេបន្តដំណើរដល់ពេលព្រលប់ ទើបឃើញកំពូលភ្នំខ្ពស់សន្ធឹមនិងដបូលផ្ទុះហាច្រើន, ប៉ាយ
អាន់ជាន:ពាល:

_ លោកម្ចាស់ភូមិ , នេះជាភ្នំចិចកកហើយ ។ យើងនៅធ្វាយអាច់ស្រយាលតាស្រុ
ភូមិទើបមិនបានតុបតែងអ្វីឲ្យល្អទេ ។

ស៊ីឈីសរសើរ:

_ ភ្នំខ្ពស់ហើយមានចិចកកសស្តុះដូចកម្រាលសំបី សក្តិសមនឹងឈ្មោះក្រុមហ៊ុនលោកជាំ
ខែមន !

នៅតាមចង្កេះភ្នំឃើញសុទ្ធតែចិចកកនិងអ័ព្ទសត្រាកហាក់ដូចស្ថិតនៅលើស្ថានសួគ៌ ជុំវិញល
ពពកសប្បាស ។ លុះក្រឡេកមើលទៅក្រោមឃើញស្រអាប់ផតយល់អ្វីឡើយ ។ ពេលនេះមេ
ធនីតឈីង គោងឈប់សម្រាកក្នុងផ្ទះថ្មពីរធំៗ សងខាងផ្ទះម្ដងនៅទៀត ។ នេះសុទ្ធជាសំណង់របស់ក្រ
ភ្នំចិចកកសម្រាប់ជូនអ្នកធ្វើដំណើរសម្រាកកម្លាំង ដើម្បីបន្តដំណើរឡើងទៅកាន់ចំការភ្នំចិចកក ។

ស្មែកឡើងភ្លឺស្រាង ។ គេរៀបចំចេញដំណើរចាំងព្រឹកព្រលឹម ។ មើលតាមចម្ងាយឃើញ
ជាមិនខ្ពស់មិនពិបាកឡើងទេ . ដល់ធ្វើដំណើរផ្ទាល់ទើបដឹងថា ផ្លូវដើរជាប់ពិបាកឡើងទៅវិញ
ប៉ុន្តែអ្នកចាំងអស់ចេះហ៊ុនសិល្បៈប្រចាំកាយ គេឈប់ស្រស់ស្រួបរាល់តែពីរដងតាមចង្កេះភ្នំក៏បន្ត
ណើរទៅទៀតដល់កំពូលភ្នំចិចកកនៅពេលរសៀល ។

លើកំពូលភ្នំមានវាលរាបធំល្វឹងល្វើយ, មានផ្ទះច្រនខ្នងព័ទ្ធទៅហោយរបងឫកំពស់ជាងបីម៉ែ
ជាប់ជាផ្ទះចិចកកសត្រាត ។

(នៅមានត)

ពាល់តាមលេខ ៣៤៣ ចុះថ្ងៃទី ៥ ខែ ៧ ឆ្នាំ ៧០ ថោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers